# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 14-Jan-2015, 11:48
CMS/CFO: Sann Rada

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ: មេធាវីការពារក្តីជនសង្ស័យមួយរូបដែលមានឈ្មោះក្នុងសំណុំរឿង ០០៤

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១២ ខែ មករា ឆ្នាំ២០១៥

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ : សាធារណៈ/Public

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សំណើសុំដាក់សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តី ស្តីពីសហឧក្រិដ្ឋកម្មរួម

---

**ដាក់ដោយ៖**

**សហមេធាវី៖**

សូ មូស្សេវិនីច

Suzana TOMANOVIĆ

**ផ្ញើជូន៖**

**ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម **គង់ ស្រ៊ឹម** ជាប្រធាន

ចៅក្រម **សោម សិរីវឌ្ឍ**

ចៅក្រម **ម៉ុង មុន្នីចរិយា**

ចៅក្រម **យ៉ា ណារិន**

ចៅក្រម Florence Ndepele Mwachande MUMBA

ចៅក្រម Agnieszka KLONOWIECKA-MILART

ចៅក្រម Chandra Nihal JAYASINGHE

**សហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

អនុលោមតាមវិធាន ២១ និង ៣៣ នៃវិធានផ្ទៃក្នុង អ.វ.ត.ក (“វិធាន”) តាមរយៈសហមេធាវីរបស់ខ្លួន (“មេធាវីការពារក្តី”) ជនសង្ស័យមួយរូបដែលមានឈ្មោះក្នុងសំណុំរឿង ០០៤ សូមដាក់សារណារបស់អ្នកមិនមែនជាភាគីរឿងក្តី (“សារណារបស់អ្នកមិនមែនជាភាគីរឿងក្តី”) (សូមមើល ឧបសម្ព័ន្ធ ក) ដើម្បីជួយអង្គជំនុំជម្រះតុលាការកំពូល ក្នុងការសម្រេចទៅលើសំណើរបស់សហព្រះរាជអាជ្ញាសុំអនុវត្តទម្រង់ពង្រីកនៃសហឧក្រិដ្ឋកម្មរួម (“JCE III”) នៅ អ.វ.ត.ក (“សំណើរបស់ ក.ស.ព”)[1]។ ជាងនេះទៀត ដើម្បីជួយអង្គជំនុំជម្រះតុលាការកំពូល សារណារបស់អ្នកមិនមែនជាភាគីរឿងក្តីត្រូវពិនិត្យលើសុពលភាពនៃសហឧក្រិដ្ឋកម្មរួម (“JCE III”)ជាទម្រង់មានសុពលភាពនៃការទទួលខុសត្រូវនៅអ.វ.ត.ក។ សារណារបស់អ្នកមិនមែនជាភាគីរឿងក្តីត្រូវធ្វើឡើងជាការចាំបាច់ ដោយសារសំណើរបស់ ក.ស.ព រំលោភបំពានទៅលើសិទ្ធិជាសារវ័ន្តរបស់ជនសង្ស័យ ដោយមានបំណងចង់ឲ្យអង្គជំនុំជម្រះប្រកាសថាទម្រង់នៃការទទួលខុសត្រូវមួយអាចអនុវត្តបាននៅ អ.វ.ត.ក ហើយវាក៏អាចអនុវត្តចំពោះជនសង្ស័យដែរ ដែលមិនមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ទេ។ អនុលោមតាមមាត្រា ៨.៣ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ ចម្លើយតបណាមួយត្រូវដាក់ “ក្នុងរយៈពេល ១០ (ដប់ថ្ងៃ) ថ្ងៃប្រតិទិន គិតពីថ្ងៃជូនដំណឹងនៃឯកសារដែលត្រូវឆ្លើយតប”[2]។ សារណារបស់អ្នកមិនមែនជាភាគីរឿងក្តីមិនមែនជាការឆ្លើយតបទេ ប៉ុន្តែការឆ្លើយតបនានាត្រូវបានអនុញ្ញាតឲ្យដាក់ជាសារណារបស់អ្នកមិនមែនជាភាគីរឿងក្តីបាន[3]។

## I. ភាពទទួលយកបាននៃសារណារបស់អ្នកមិនមែនជាភាគីរឿងក្តី

1. សារណារបស់អ្នកមិនមែនជាភាគីរឿងក្តីអាចទទួលយកបានតាមវិធាន ២១។ អង្គបុរេជំនុំជម្រះធ្លាប់បានពិចារណាថា គោលការណ៍ជាសារវ័ន្តដែលមានចែងក្នុងវិធាន ២១ “តម្រូវថា អង្គបុរេជំនុំជម្រះត្រូវបកស្រាយឲ្យបានទូលំទូលាយ នូវសិទ្ធិរបស់ជនជាប់ចោទក្នុងការប្តឹងឧទ្ធរណ៍ ដើម្បីធានាថា សិទ្ធិរបស់

---

[1] *សំណុំរឿង ០០២* បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿងលេខ ០០២/០១ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ F11។

[2] *សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/វិ.លើកទី៨* ការដាក់ឯកសារនៅ អ.វ.ត.ក មាត្រា ៨.៣។

[3] វិធាន ៣៣(២) ចែងក្នុងផ្នែកពាក់ព័ន្ធថា៖ “សារណាដែលធ្វើឡើងក្រោមវិធាននេះ ត្រូវប្រគល់ទៅឲ្យក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះដែលពាក់ព័ន្ធ ហើយក្រឡាបញ្ជីត្រូវប្រគល់ឯកសារថតចម្លងមួយច្បាប់ទៅឲ្យសហព្រះរាជអាជ្ញា និង មេធាវីរបស់ភាគីដទៃទៀត ដើម្បីមានឱកាសធ្វើការឆ្លើយតប”។

ជនជាប់ចោទក្នុងការទទួលបានការកាត់សេចក្ដីដោយយុត្តិធម៌ ត្រូវបានគាំពារក្នុងកាលៈទេសៈនេះ”[4]។ អង្គបុរេជំនុំជម្រះបានទទួលយកបណ្ដឹងឧទ្ធរណ៍ដែលបានលើកឡើងនូវបញ្ហាសិទ្ធិជាសារវ័ន្តនៃការកាត់សេចក្ដីដោយយុត្តិធម៌ ទៅលើមូលដ្ឋាននៃវិធាន ២១ តែមួយ[5]។ វិធាន ២១ ក៏អាចអនុវត្តបានចំពោះជនសង្ស័យដែរ ហើយហេតុនេះ ការបកស្រាយយ៉ាងទូលំទូលាយរបស់អង្គបុរេជំនុំជម្រះក៏គួរតែអនុវត្តចំពោះជនសង្ស័យដែរ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា ជនសង្ស័យមានសិទ្ធិនានាដែលមានចែងក្នុងវិធាន ២១[6]។

2. វិធាន ២១ ចែងថា “ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្ដីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព...”។ ជនសង្ស័យមានសិទ្ធិជាសារវ័ន្តក្នុងការទទួលការកាត់សេចក្ដីតាមច្បាប់ជាធរមានក្នុងពេលដែលបទល្មើសត្រូវបានចោទប្រកាន់តែប៉ុណ្ណោះ និងសិទ្ធិទទួលបានសម

[4] *សំណុំរឿង ០០២* សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្ដីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងសេចក្ដីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D390/1/2/4 (“សាលដីកាលើចម្លើយតបរបស់ អៀង សារី”) កថាខណ្ឌ ១៣។ *សូមមើលផងដែរ សំណុំរឿង ០០២* សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្ដីពីសិទ្ធិ និង កាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៨ ឯកសារ A190/I/20 កថាខណ្ឌ ៣៦។ *សំណុំរឿង ០០២* សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដោះស្រាយ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ៤៩។

[5] *សូមមើលឧទាហរណ៍ សំណុំរឿង ០០២* សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធលើសំណើសុំព្យួរកិច្ចស៊ើបសួរ ដោយមូលហេតុរំលោភនីតិវិធី ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១០ ឯកសារ D264/2/6 កថាខណ្ឌ ១៣ ដល់ ១៤។ សាលដីកាលើចម្លើយតបរបស់ អៀង សារី កថាខណ្ឌ ១៣។

[6] “អាស្រ័យហេតុនេះ សិទ្ធិរបស់ជនសង្ស័យ ក្នុងការ “បញ្ចេញយោបល់” នៅដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី គ្រាន់តែមានត្រឹមសិទ្ធិដែលទទួលបានដោយជនសង្ស័យ ដូចមានចែងនៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុងតែប៉ុណ្ណោះ” *សំណុំរឿង ០០៤* ដីកាសម្រេចលើសំណើរបស់ [redacted] ទៅសហចៅក្រមស៊ើបអង្កេតសុំបង្គាប់ទៅក្រឡាបញ្ជីរបស់ ក.ស.ច.ស ឱ្យបញ្ចូលនូវការដាក់ឯកសាររបស់មេធាវីការពារក្ដីទៅក្នុងសំណុំរឿងភ្លាម ចុះថ្ងៃទី ៤ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ D202/2 កថាខណ្ឌ ៦។

ភាពនៃមធ្យោបាយរវាងគូភាគីក្នុងការតទល់ក្តី ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ[7] កិច្ចព្រមព្រៀង[8] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[9] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR")[10] និង វិធាន[11]។

3. នៅក្នុងសេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ សហព្រះរាជអាជ្ញាបានលើកឡើងថា "ពួកគេមិនមានបំណងប្តឹងសាទុក្ខចំពោះសេចក្តីសម្រេចលើផ្នែកបញ្ញត្តិនៃសាលក្រម ឬលើការរកឃើញផ្នែកអង្គហេតុ និង

---

[7] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាចែងថា៖ "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីសម្រេចជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"។ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញចែងថា៖ "ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់"។

[8] មាត្រា ១២(២) នៃកិច្ចព្រមព្រៀង ចែងក្នុងផ្នែកពាក់ព័ន្ធថា៖ "អង្គជំនុំជម្រះវិសាមញ្ញត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ [ICCPR] ដែលកម្ពុជាគឺជាភាគីហត្ថលេខីដែរ"។ មាត្រា ១៣(១) នៃកិច្ចព្រមព្រៀងចែងក្នុងផ្នែកពាក់ព័ន្ធថា៖ "សិទ្ធិរបស់ជនជាប់ចោទ ដែលមានចែងនៅក្នុងមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវតែបានគោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្តី។ សិទ្ធិបែបនេះជាពិសេស រួមមានសិទ្ធិទទួលបាននូវសវនាការមួយត្រឹមត្រូវ និងជាសាធារណៈ"។

[9] មាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងក្នុងផ្នែកពាក់ព័ន្ធថា៖ "អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ ...។ អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្រប តាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវនឹងដំណើរការសមស្របនៃច្បាប់ដូចដែលបានចែងក្នុងមាត្រា១៤ និង១៥ នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ"។

[10] មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងក្នុងផ្នែកពាក់ព័ន្ធថា៖ "ជនគ្រប់រូបត្រូវមានសិទ្ធិឱ្យសាលាក្តីមានសមត្ថកិច្ចឯករាជ្យ និងមិនលំអៀង ដែលបង្កើតឡើងដោយច្បាប់ជំនុំជម្រះរឿងក្តីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈ"។ មាត្រា ១៥(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងក្នុងផ្នែកពាក់ព័ន្ធថា៖ "គ្មានជនណាម្នាក់ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌចំពោះអំពើ ឬការខកខានណាមួយ ដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិក្នុងខណៈពេលប្រព្រឹត្តនោះឡើយ"។

[11] វិធាន ២១(១)(ក) ចែងក្នុងផ្នែកពាក់ព័ន្ធថា៖ "ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ"។

អង្គច្បាប់ នៅក្នុងសាលក្រមនោះឡើយ”[12] តែថា ពួកគេដាក់សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ “ដើម្បីជាផលប្រយោជន៍ដល់ច្បាប់”[13]។ សហព្រះរាជអាជ្ញាបញ្ជាក់ច្បាស់ថា គោលបំណងនៃសំណើរបស់ ក.ស.ព គឺដើម្បីជាប្រយោជន៍នៃរឿងក្តីរបស់ខ្លួនក្នុងសំណុំរឿង ០០២/០២[14]។ ខ្លឹមសារនៃសំណើរបស់ ក.ស.ព នឹងមិនមានអ្វីពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ទេ តែមានសក្តានុពលមានឥទ្ធិពលទៅលើយុត្តិសាស្ត្រទាំងមូលរបស់ អ.វ.ត.ក រួមទាំងច្បាប់ដែលអនុវត្តចំពោះជនសង្ស័យ។ ដើម្បីការពារសិទ្ធិជាសារវ័ន្តរបស់ជនសង្ស័យក្នុងការទទួលការកាត់សេចក្តីតាមច្បាប់ជាធរមាននៅពេលដែលបទល្មើសត្រូវបានចោទប្រកាន់តែប៉ុណ្ណោះ និងសិទ្ធិទទួលបានសមភាពនៃមធ្យោបាយរវាងគូភាគីក្នុងការតទល់ក្តី គាត់ត្រូវតែទទួលបានការអនុញ្ញាតឆ្លើយតបតាមរយៈសារណារបស់អ្នកមិនមែនជាភាគីរឿងក្តី ទៅនឹងសំណើរបស់ ក.ស.ព ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា សំណើរបស់ ក.ស.ព អាចទទួលយកបាន។ ប្រសិនបើមិនអាចដាក់សារណារបស់អ្នកមិនមែនជាភាគីរឿងក្តីបាន ជនសង្ស័យមិនអាចការពារខ្លួនចំពោះផលប៉ះពាល់ដែលអាចកើតមាន ដែលរំលោភបំពានដល់សិទ្ធិជាសារវ័ន្តរបស់គាត់ក្នុងការទទួលបានសម្ភារៈរូបវ័ន្តសម្រាប់រៀបចំការពារខ្លួន[15]។

## II. សំណើរបស់ ក.ស.ព មិនអាចទទួលយកបានទេ

[12] *សំណុំរឿង ០០២* សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា ស្តីពីបណ្តឹងសាទុក្ខ ចំពោះសេចក្តីសម្រេចនៅក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ E313/3/1 (“សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ”) កថាខណ្ឌ ១០។

[13] សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ កថាខណ្ឌ ២។

[14] “សហព្រះរាជអាជ្ញានឹងស្នើសុំឲ្យអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី III សម្រាប់បទចោទផ្សេងៗដែលកំពុងត្រូវបានពិនិត្យនៅក្នុងសំណុំរឿង ០០២/០២ ដែលសហព្រះរាជអាជ្ញាយល់ថាជាការត្រឹមត្រូវផ្នែកអង្គហេតុដែលត្រូវបានកំណត់ក្នុងសហឧក្រិដ្ឋកម្មទម្រង់ទី III ដែលនេះជាការកំណត់ប្រភេទបទល្មើស *ម្យ៉ាងទៀត*ចំពោះការប្រព្រឹត្តិរបស់សហជនជាប់ចោទ” សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ កថាខណ្ឌ ៨(២)។

[15] មាត្រា ៣៥ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងក្នុងផ្នែកពាក់ព័ន្ធថា៖ “នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និងស្មើៗគ្នាសមស្របតាមមាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ១៩៦៦៖ ... ខ/ មានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ ដើម្បីរៀបចំការពារខ្លួន និងទាក់ទងជាមួយមេធាវីរបស់ខ្លួនដែលជ្រើសរើសដោយខ្លួនឯង...”។ មាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងក្នុងផ្នែកពាក់ព័ន្ធថា៖ “ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរិមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ដូចខាងក្រោម៖ ... (ខ) ត្រូវមានពេលវេលា និងសម្ភារៈរូបវ័ន្តគ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយមេធាវីដែលជ្រើសរើសដោយខ្លួនឯង ...”។

## ក. សហព្រះរាជអាជ្ញាមិនបានបំពេញតាមបទដ្ឋានដែលមានចែងក្នុងវិធាន

4. សហព្រះរាជអាជ្ញាបានលើកឡើងថា ពួកគេ "ដាក់បណ្តឹងសាទុក្ខនេះជូនអង្គជំនុំជម្រះតុលាការកំពូល ... ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១"[16]។ ពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម វិធាន ១០៤ ដែលមានចំណងជើងថា "យុត្តាធិការនៃអង្គជំនុំជម្រះតុលាការកំពូល" ចែងនៅក្នុងអនុផ្នែកទី ១ ថា៖

> អង្គជំនុំជម្រះតុលាការកំពូលត្រូវសម្រេចលើបណ្តឹងសាទុក្ខ ជំទាស់ទៅនឹងសាលក្រមលើអង្គសេចក្តីឬសេចក្តីសម្រេចនៃអង្គជំនុំជម្រះសាលាដំបូង ដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម៖
> ក. កំហុសលើអង្គច្បាប់ ដែលនាំអោយមោឃ: សាលក្រមលើអង្គសេចក្តី ឬ សេចក្តីសម្រេចនោះ។ ឬ
> ខ. កំហុសនៃអង្គហេតុ ដែលនាំអោយសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនោះមានភាពមិនយុត្តិធម៌។

សហព្រះរាជអាជ្ញាមិនអាចបង្ហាញនូវកំហុសណាមួយដែលនាំឲ្យមោឃៈសាលក្រមទេ។ ការពិត សហព្រះរាជអាជ្ញាបានលើកឡើងយ៉ាងច្បាស់ថា "ពួកគេមិនមានបំណងប្តឹងសាទុក្ខចំពោះសេចក្តីសម្រេចលើផ្នែកបញ្ញត្តិនៃសាលក្រម ឬលើការរកឃើញផ្អែកអង្គហេតុ និងអង្គច្បាប់ នៅក្នុងសាលក្រមនោះឡើយ"[17]។

5. សហព្រះរាជអាជ្ញាដាក់សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ "អនុលោមតាមវិធាន ១០៥(៣) នៃវិធានផ្ទៃក្នុង"[18]។ វិធាន ១០៥(៣) ចែងថា៖

> ភាគីដែលមានបំណងប្តឹងសាទុក្ខចំពោះសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ដោយបញ្ជាក់ពីមូលដ្ឋាននៃបណ្តឹងសាទុក្ខនោះ។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ដែលបញ្ជាក់ពីមូលដ្ឋាននីមួយៗ ត្រូវបញ្ជាក់ពីកំហុសអង្គច្បាប់

---

[16] សំណើរបស់ ក.ស.ព កថាខណ្ឌ ១។

[17] សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ កថាខណ្ឌ ១០។

[18] សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ កថាខណ្ឌ ១។

ដែលនាំឲ្យសេចក្តីសម្រេចនោះមោឃៈ និង កំហុសអង្គហេតុ ដែលនាំឲ្យសេចក្តីសម្រេចនោះមានភាពមិនយុត្តិធម៌។ បន្ទាប់មកម្ចាស់បណ្តឹងសាទុក្ខ ត្រូវដាក់សារណាបណ្តឹងសាទុក្ខ ដោយបញ្ជាក់ពីទឡ្ហីករណ៍ និងឯកសារសម្អាងផ្លូវច្បាប់ ដែលគាំទ្រមូលដ្ឋាននីមួយៗ អនុលោមតាមលក្ខខណ្ឌនៅក្នុងវាក្យខណ្ឌទី ២ (ក) និង (គ) នៃវិធាននេះ។

វិធាន ១០៥(៣) ចែងច្បាស់ថា មូលដ្ឋាននីមួយៗនៃបណ្តឹងសាទុក្ខ គួរបញ្ជាក់ពី "កំហុសអង្គច្បាប់" ឬ "កំហុសអង្គហេតុ"។ ប៉ុន្តែ សហព្រះរាជអាជ្ញាលើកឡើងថា ពួកគេដាក់សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ "ដើម្បីជាផលប្រយោជន៍ដល់ច្បាប់"[19]។ ការដាក់បណ្តឹងសាទុក្ខដើម្បីជាផលប្រយោជន៍ដល់ច្បាប់ មិនស្របទៅនឹងលក្ខខណ្ឌវិនិច្ឆ័យដែលមានចែងក្នុងវិធាន ១០៥(៣) ទេ។

6. សំណើរបស់ ក.ស.ព មានភាពខ្វះចន្លោះផ្នែកនីតិវិធី។ សហព្រះរាជអាជ្ញាដាក់សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។ អនុលោមតាមវិធាន ១០៦(២) ការជូនដំណឹងពីបណ្តឹងសាទុក្ខ "ត្រូវដាក់ជូនក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង"។ ហេតុនេះ សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខមិនមានសុពលភាពទេ ហើយសហព្រះរាជអាជ្ញាត្រូវបានរារាំងដោយនីតិវិធីក្នុងការដាក់បណ្តឹងសាទុក្ខដែលពាក់ព័ន្ធនឹងសេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ។

## ខ. វិធានស្តីពីនីតិវិធីដែលបានបង្កើតឡើងនៅក្នុងកម្រិតអន្តរជាតិមិនគាំទ្រដល់ការទទួលយកសំណើរបស់ ក.ស.ព ទេ

7. "ជំហរនៅក្នុងការទទួលយក" របស់សហព្រះរាជអាជ្ញាគឺថា បញ្ហានេះអាចទទួលយកបានតាម "វិធានស្តីពីនីតិវិធីដែលបានបង្កើតឡើងនៅក្នុងកម្រិតអន្តរជាតិ"[20]។ មាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងច្បាស់ថា នីតិវិធីនៅ អ.វ.ត.ក ត្រូវតែ "ប្រព្រឹត្តទៅតាមនីតិវិធីជាធរមាន" និង ក្នុងករណី "បើនីតិវិធី ដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើត

[19] សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ កថាខណ្ឌ ២។

[20] សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ កថាខណ្ឌ ៥។ *សូមមើលផងដែរ* សំណើរបស់ ក.ស.ព កថាខណ្ឌ ៧ ដល់ ៨។

ឡើងក្នុងកម្រិតអន្តរជាតិ"។ នីតិវិធីដែលមានស្រាប់ ជាទម្រង់ដែលមានចែងក្នុងវិធាន ១០៤(១) និង ១០៥(៣) ចែងច្បាស់ថា បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងអាចដាក់បាន ផ្អែកលើមូលដ្ឋាននៃ "កំហុសអង្គច្បាប់" ឬ "កំហុសអង្គហេតុ" តែប៉ុណ្ណោះ។ សហព្រះរាជអាជ្ញាមិន បានលើកឡើងនូវកំហុសណាមួយក្នុងចំណោមកំហុសទាំងនេះទេ។ នៅក្នុងករណីនេះ គេពុំចាំបាច់ ស្វែងរកការណែនាំពីវិធានស្ដីពីនីតិវិធីដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិ ដើម្បីអនុញ្ញាតឱ្យមាន សំណើរបស់ ក.ស.ព ទេ។

8. បើទោះបីវិធានស្ដីពីនីតិវិធីដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិត្រូវបានយកមកពិចារណាក៏ដោយ ក៏ប្រការនេះមិនអាចឱ្យសំណើរបស់ ក.ស.ព ទទួលយកបានដែរ។ យុត្តិសាស្ត្រដែលត្រូវបានដកស្រង់ ដោយសហព្រះរាជអាជ្ញាមិនបានជួយដល់ករណីនេះទេ។ ដូចដែលសហព្រះរាជអាជ្ញាបានលើកឡើង រួចមកហើយគឺថា អង្គជំនុំជម្រះតុលាការកំពូល (ដែលឆ្លុះបញ្ចាំងពីយុត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌ អន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("ICTY") និង តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ ប្រទេសរវ៉ាន់ដា ("ICTR")) បានសន្និដ្ឋានថា "ក្នុងកាលៈទេសៈពិសេស អង្គជំនុំជម្រះតុលាការកំពូល អាចលើកបញ្ហាឡើងតាមគំនិតផ្ដួចផ្ដើមរបស់ខ្លួន *(ex proprio motu)* ឬស្ដាប់សវនាការលើបណ្ដឹង សាទុក្ខដែលភាគីបានលើកឡើងពីបញ្ហាអង្គច្បាប់ ដែលមិនត្រឹមតែមិនធ្វើឱ្យសាលក្រមមោឃៈប៉ុណ្ណោះ ទេ ប៉ុន្តែថែមទាំងផ្ដល់នូវសារៈសំខាន់ជាទូទៅសម្រាប់យុត្តិសាស្ត្ររបស់ អ.វ.ត.ក ទៀតផង"[21]។

9. នៅក្នុងករណីនេះ ការពិចារណាសាជាថ្មីចំពោះការអនុវត្តសហឧក្រិដ្ឋកម្មទម្រង់ទី III នៅ អ.វ.ត.ក មិនមែនជាចំណុចសំខាន់ទូទៅចំពោះយុត្តិសាស្ត្រនៅ អ.វ.ត.ក ទេ។ យុត្តិសាស្ត្រនៅ អ.វ.ត.ក ត្រូវបាន ដោះស្រាយរួចហើយលើបញ្ហានេះ។ អង្គបុរេជំនុំជម្រះបានធ្វើការវិភាគយ៉ាងលំអិតទៅលើស្ថានភាពនៃ ច្បាប់ទំនៀមទម្លាប់អន្តរជាតិពាក់ព័ន្ធនឹងអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី III ក្នុងអំឡុងយុត្តាធិ ការពេលវេលារបស់ អ.វ.ត.ក ហើយបានសន្និដ្ឋានថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី III ពុំមានអត្ថិភាព ទេ ("សេចក្ដីសម្រេចរបស់ អ.ប.ជ ស្ដីពីសហឧក្រិដ្ឋកម្មរួមទម្រង់ទី III")[22]។ អង្គជំនុំជម្រះសាលា

---

[21] *សំណុំរឿង ០០១* សាលដីកា ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ១៥។

[22] *សំណុំរឿង ០០២* សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហ ឧក្រិដ្ឋកម្ម (JCE) ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ ឯកសារ D97/14/15។

ដំបូងបានតម្កល់សេចក្តីសន្និដ្ឋានរបស់អង្គបុរេជំនុំជម្រះ[23]។ អង្គជំនុំជម្រះតុលាការកំពូលមិនបានសន្និដ្ឋានថា កាលៈទេសៈជុំវិញសហឧក្រិដ្ឋកម្មទម្រង់ទី III ជាកាលៈទេសៈ "ពិសេស" ទេ។ សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០១ ត្រូវបានចេញ ក្រោយសេចក្តីសម្រេចរបស់ អ.ប.ជ ស្តីពីសហឧក្រិដ្ឋកម្មរួមទម្រង់ទី III[24]។ ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលលើកឡើងនូវលក្ខណៈពិសេសនៃសេចក្តីសម្រេចរបស់ អ.ប.ជ ស្តីពីសហឧក្រិដ្ឋកម្មរួមទម្រង់ទី III អង្គជំនុំជម្រះនឹងលើកឡើងតាមគំនិតផ្តួចផ្តើមរបស់ខ្លួន *(proprio motu)* នូវ បញ្ហាដែលមានសារៈសំខាន់ជាទូទៅចំពោះយុត្តិសាស្ត្រនៅ អ.វ.ត.ក មិនខាន។

10. សហព្រះរាជអាជ្ញាអះអាងថា "ជំហរនេះក៏ត្រូវបានបង្កើតឡើងយ៉ាងល្អដែរនៅក្នុងច្បាប់របស់ប្រទេសបារាំង តាមរយៈដំណោះស្រាយតាមផ្លូវច្បាប់វិសាមញ្ញដែលហៅថា *pourvoi en cassation dans l'intérêt de la loi*"[25]។ ជាងនេះទៀត សហព្រះរាជអាជ្ញាអះអាងថា "ក្នុងនាមជាស្ថាប័នតុលាការកំពូលរបស់ អ.វ.ត.ក អង្គជំនុំជម្រះនេះគួរប្រើសិទ្ធិអំណាចដូចគ្នាដែលមាននៅក្រោមច្បាប់កម្ពុជា ក្នុងការដោះស្រាយបញ្ហាច្បាប់ទាំងឡាយដែលមានលក្ខណៈចាប់បង្ខំ បើទោះជាវាមិនប៉ះពាល់ដល់សាលក្រមស្ថាពរក៏ដោយ"[26]។ អ.វ.ត.ក ជាតុលាការកម្ពុជាដែលអនុវត្តច្បាប់កម្ពុជា។ ពុំមានបញ្ញត្តិណាមួយនៅក្នុងច្បាប់កម្ពុជាដែលអនុញ្ញាតឱ្យធ្វើសំណូមពរ តាមរយៈតុលាការកំពូលទៅលើបញ្ហាផ្លូវច្បាប់ដែលមានសារៈសំខាន់ទូទៅ ឬសារៈសំខាន់ច្រើននៅក្នុងយុត្តិសាស្ត្ររបស់កម្ពុជាទេ។ នៅពេលមានភាពមិនច្បាស់លាស់កើតឡើង សេចក្តីណែនាំពីយុត្តាធិការតុលាការថ្នាក់ជាតិរបស់ប្រទេសផ្សេងទៀតអាចមានប្រយោជន៍ដែរ។ នៅក្នុងករណីនេះ ពុំចាំបាច់មានសេចក្តីណែនាំពីយុត្តាធិការតុលាការថ្នាក់ជាតិរបស់ប្រទេសផ្សេងទៀតទេ ដោយសារយុត្តិសាស្ត្រនៅ អ.វ.ត.ក លើបញ្ហានេះមានភាពច្បាស់លាស់ និងត្រូវបានដោះស្រាយរួចរាល់ហើយ។

---

[23] *សំណុំរឿង ០០២* សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ E100/6 ("សេចក្តីសម្រេចរបស់ អ.ប.ជ ស្តីពីសហឧក្រិដ្ឋកម្មទម្រង់ទី III")។

[24] សេចក្តីសម្រេចរបស់ អ.ប.ជ ស្តីពីសហឧក្រិដ្ឋកម្មទម្រង់ទី III ត្រូវបានចេញត្រូវបានចេញនៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០។ សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០១ ត្រូវបានចេញនៅថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២។

[25] សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ កថាខណ្ឌ ៥។

[26] សំណើរបស់ ក.ស.ព កថាខណ្ឌ ៩។

## គ. ការលើកឡើងផ្សេងៗពីភាពទទួលយកបានរបស់សហព្រះរាជអាជ្ញា ពុំមានមូលដ្ឋានសំអាងទេ

11. សហព្រះរាជអាជ្ញាអះអាងដោយមិនត្រឹមត្រូវថា "អវត្តមាននៃការទទួលយកបណ្ដឹងសាទុក្ខនៅដំណាក់កាលនេះ មានន័យថា អង្គជំនុំជម្រះនេះនឹងគ្មានអំណាចក្នុងការដោះស្រាយបញ្ហាដែលមានសារៈសំខាន់ជាទូទៅនេះទេ ទាក់ទិននឹងការអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី III នេះ"[27]។ នៅពេលការអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី III សំដៅដល់តេស្តដែលមានចែងក្នុងវិធាន ១០៤ នោះសហព្រះរាជអាជ្ញានឹងមានឧបករណ៍ផ្លូវច្បាប់ត្រឹមត្រូវក្នុងការនាំយកសហឧក្រិដ្ឋកម្មរួមមកចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលបាន។ សហព្រះរាជអាជ្ញាលើកឡើងថា ពួកគេ "នឹងស្នើសុំឲ្យអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី III សម្រាប់បទចោទផ្សេងៗដែលកំពុងត្រូវបានពិនិត្យនៅក្នុងសំណុំរឿង ០០២/០២"[28]។ តាមរយៈវិធាន ១០៤ ប្រសិនបើបញ្ហានេះលើកឡើងក្នុងសំណុំរឿង ០០២/០២ នោះសហព្រះរាជអាជ្ញានឹងមានឧបករណ៍ផ្លូវច្បាប់ត្រឹមត្រូវដើម្បីលើកឡើងនូវការអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី III នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០២ បាន។

12. សហព្រះរាជអាជ្ញាអះអាងថា "ការពិចារណាដែលមានលក្ខណៈចាប់បង្ខំចំពោះគោលនយោបាយសាធារណៈជាអន្តរជាតិ តម្រូវឲ្យមានការពិនិត្យដោយអង្គជំនុំជម្រះនេះ ដូចមានចែងក្នុងសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា"[29]។ សហព្រះរាជអាជ្ញាផ្ដល់សំអាងហេតុចំនួនប្រាំសម្រាប់ការស្នើសុំ "ការណែនាំផ្លូវច្បាប់ជាក់លាក់" ពីអង្គជំនុំជម្រះតុលាការកំពូល។ សំអាងហេតុនីមួយៗនឹងត្រូវលើកយកមកពិភាក្សាមួយម្ដងៗ។

13. ដំបូងសហព្រះរាជអាជ្ញាអះអាងថា "ការអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី III ត្រូវបានអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូងពិចារណា ប៉ុន្តែអង្គជំនុំជម្រះតុលាការកំពូលមិនទាន់បានដោះស្រាយបញ្ហានេះឲ្យបានច្បាស់លាស់នៅក្នុងសំណុំរឿង ០០១ និង សំណុំរឿង ០០២ នៅឡើយទេ"[30]។ អត្ថិភាពនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី III នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងពេលយុត្តា

---

[27] សំណើរបស់ ក.ស.ព កថាខណ្ឌ ១០។

[28] សេចក្ដីជូនដំណឹងពីបណ្ដឹងសាទុក្ខ កថាខណ្ឌ ៨(២)។

[29] សំណើរបស់ ក.ស.ព កថាខណ្ឌ ១១។

[30] សេចក្ដីជូនដំណឹងពីបណ្ដឹងសាទុក្ខ កថាខណ្ឌ ៨(១)។

ធិការពេលវេលារបស់ អ.វ.ត.ក មិនមែនជាបញ្ហាច្បាប់ដែលមិនទាន់បានដោះស្រាយទេ។ ទាំងអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូងបានយល់ស្របគ្នាថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី III មិនអាចអនុវត្តបាននៅ អ.វ.ត.ក ទេ[31]។ អង្គជំនុំជម្រះតុលាការកំពូលពុំចាំបាច់ដោះស្រាយបញ្ហាដែលមានគោលបំណងបង្ហាញពីសច្ចភាពផ្លូវច្បាប់ទេ។ ផ្ទុយទៅវិញ ការរំខានដល់អង្គជំនុំជម្រះតុលាការកំពូលចំពោះយុត្តិសាស្ត្រដែលបានដោះស្រាយរួចហើយនោះនឹងនាំឱ្យមានអសច្ចភាពផ្លូវច្បាប់ទៅវិញទេ។ សហព្រះរាជអាជ្ញាមានកំហុសដែលអះអាងថា បញ្ហានេះមិនទាន់ត្រូវបានដោះស្រាយ ដោយសារអង្គជំនុំជម្រះតុលាការកំពូលមិនទាន់យកទៅពិចារណា។ អង្គជំនុំជម្រះតុលាការកំពូលមិនបានសន្និដ្ឋាននេះ បញ្ហានេះ "មានលក្ខណៈពិសេស" ឬ "សារៈសំខាន់ជាទូទៅ" ដើម្បីលើកឡើងនូវបញ្ហានេះតាមគំនិតផ្តួចផ្តើមរបស់ខ្លួន *(proprio motu)* នៅពេលអង្គជំនុំជម្រះមានឱកាសបែបនេះក្នុងសំណុំរឿង ០០១។

14. ទីពីរ សហព្រះរាជអាជ្ញាអះអាងថា "សហជនជាប់ចោទត្រូវបានជូនដំណឹង ព្រោះថានៅក្នុងសវនាការបឋមបន្ថែមកាលពីថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញានឹងស្នើសុំឱ្យអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី III សម្រាប់បទចោទផ្សេងៗដែលកំពុងត្រូវបានពិនិត្យនៅក្នុងសំណុំរឿង ០០២/០២"[32]។ ចំណុចនេះមិនពាក់ព័ន្ធទេ។ ដូចបានលើកឡើង*ខាងលើ*រួចមកហើយ បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមដែលមិនត្រូវលើកឡើងដោយផ្អែកលើ "កំហុសអង្គច្បាប់" ឬ "កំហុសអង្គហេតុ" មិនអាចទទួលយកបានទេ។ ជាងនេះទៀត បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាមិនអាចត្រូវបានសន្និដ្ឋានថាទទួលយកបានទេ ដោយសារសហជនជាប់ចោទមិនត្រូវបានផ្តល់ដំណឹងថា សហព្រះរាជអាជ្ញាមិនយល់ស្របនឹងបញ្ហាផ្លូវច្បាប់ដែលពាក់ព័ន្ធនឹងរឿងក្តីរបស់ខ្លួនក្នុងសំណុំរឿង ០០២/០១។

15. ទីបី សហព្រះរាជអាជ្ញាអះអាងថា "អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR បានលើកឡើងយ៉ាងច្បាស់ថា "... អាចថាមិនមានការចោទប្រកាន់ជាសំណួរទៅលើថាតើ សហឧក្រិដ្ឋកម្មរួមទម្រង់ទី

---

[31] សេចក្តីសម្រេចរបស់ អ.ប.ជ ស្តីពីសហឧក្រិដ្ឋកម្មរួមទម្រង់ទី III។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីសហឧក្រិដ្ឋកម្មរួមទម្រង់ទី III។

[32] សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ កថាខណ្ឌ ៨(២)។

III ត្រូវបានទទួលស្គាល់យ៉ាងច្បាស់លាស់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ”[33]។ ជាងនេះទៀត សហព្រះរាជអាជ្ញាអះអាងថា[34]៖

> ទោះបីជាការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង សហឧក្រិដ្ឋកម្មរួមទម្រង់ទី III មិនមែនជាជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងរបស់កម្ពុជាប្រជាធិបតេយ្យ ត្រូវបានតម្កល់ និងអនុវត្ត នេះបានណែនាំយ៉ាងច្បាស់ថា អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY [និងអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR ក្នុង*រឿងក្តី Karemera* និងអ្នកផ្សេងទៀត និង អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ SCSL ក្នុង*រឿងក្តី Brima* និងអ្នកផ្សេងទៀត] មានកំហុសនៅក្នុងផ្តន្ទាទោសដោយផ្អែកទៅលើសហឧក្រិដ្ឋកម្មរួមទម្រង់ទី III ...។

ការលើកឡើងរបស់សហព្រះរាជអាជ្ញាមិនត្រឹមត្រូវទេ។ សហព្រះរាជអាជ្ញាត្រូវ “មានចរិតលក្ខណៈ និងស្មារតីខ្ពស់”[35]។ អនុលោមតាមភារកិច្ចផ្នែកសីលធម៌របស់ខ្លួន សហព្រះរាជអាជ្ញាគួរតែយកចិត្តទុកចំពោះថាតើ សហឧក្រិដ្ឋកម្មរួមទម្រង់ទី III បានបង្កើតជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក និងមិនត្រូវផ្តោតថាតើ ការលើកឡើងនូវការសន្និដ្ឋានផ្លូវច្បាប់ត្រឹមត្រូវនឹងនាំឲ្យមានការផ្តន្ទាទោសដោយមិនត្រឹមត្រូវនៅតុលាការផ្សេងទៀត ឬយ៉ាងណាទេ។ ការលើកឡើងនូវចំណុចនេះ សហព្រះរាជអាជ្ញាដែលជាអ្នកត្រូវ “មានចរិតលក្ខណៈ និងស្មារតីខ្ពស់” ទំនងជាស្នើសុំចៅក្រមនៅ អ.វ.ត.ក ប្រើឥទ្ធិពលទៅលើសេចក្តីសម្រេចរបស់ខ្លួនពីកត្តាខាងក្រៅដែលមិនត្រឹមត្រូវ ក្នុងការរំលោភបំពានដល់កាតព្វកិច្ចក្រមសីលធម៌របស់ខ្លួន[36]។ ក្នុងកាលៈទេសៈណាក៏ដោយ ការអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី III នៅតុលាការមិនអចិន្ត្រៃយ៍ *(ad hoc)* នៅតែមានការ

---

[33] សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ កថាខណ្ឌ ៨(៣)។

[34] សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ កថាខណ្ឌ ៨(៣)។

[35] កិច្ចព្រមព្រៀង មាត្រា ៦(២)។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ១៩។

[36] មាត្រា ១២៨ នៃរដ្ឋធម្មនុញ្ញចែងថា “អំណាចតុលាការជាអំណាចឯករាជ្យ។ អំណាចតុលាការធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ”។ មាត្រា ៣(៣) នៃ កិច្ចព្រមព្រៀង និងមាត្រា ១០ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងក្នុងផ្នែកពាក់ព័ន្ធថា ចៅក្រម៖ “ត្រូវឯករាជ្យក្នុងការបំពេញការងាររបស់ខ្លួន ហើយមិនត្រូវទទួល ឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬពីប្រភពណាមួយផ្សេងទៀតឡើយ”។

ខ្វែងយោបល់គ្នានៅឡើយ[37]។ តុលាការ ICC បានបដិសេធយ៉ាងច្បាស់ថាសហឧក្រិដ្ឋកម្មរួមមិនមែនជាទម្រង់មួយនៃការទទួលខុសត្រូវទេ[38]។

16. ទីបួន សហព្រះរាជអាជ្ញាអះអាងថា និងថា ពួកគេ "មិនឃើញមានភស្តុតាងណាមួយអំពីការវិវត្តផ្សេងៗនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៩២ ដែលបង្ហាញពីការកែប្រែណាមួយចំពោះស្ថានភាពនៃច្បាប់អន្តរជាតិទាក់ទងនឹងសហឧក្រិដ្ឋកម្មរួមទម្រង់ទី III"[39]។ សហព្រះរាជអាជ្ញាបានលើកជាទឡ្ហីករណ៍ស្រដៀងគ្នានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[40]។ អង្គជំនុំជម្រះតុលាការកំពូលបានវិភាគរឿងក្ដីនេះផ្អែកលើ *រឿងក្ដី Tadić*[41] និងតុលាការពិសេសសម្រាប់ប្រទេសលីបង់ ដើម្បីបង្ហាញពីអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី III និងបានសន្និដ្ឋានថា មូលដ្ឋានសម្រាប់ផ្តន្ទាទោសនៅក្នុងរឿងក្ដីទាំងនោះមិនអាចរកបានទេ ដោយចេញឆ្ងាយពីការសន្និដ្ឋានដែលបានធ្វើក្នុង

---

[37] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Prlić និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-04-74-T សាលដីកា ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៣ យោបល់ដោយឡែក និងជំទាស់មួយផ្នែករបស់ប្រធានតុលាការ ចៅក្រម Antonetti សាលដីកា Volume VI ទំព័រ ១០០ ដល់ ១៨២ (ភាសាអង់គ្លេស)។

[38] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Lubanga Dyilo* សំណុំរឿងលេខ ICC-01/04-01/06 សេចក្ដីសម្រេចលើការបញ្ជាក់ពីបទចោទ ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៧ (សេចក្ដីសម្រេចលើការបញ្ជាក់បទចោទក្នុងរឿងក្ដី Lubanga") កថាខណ្ឌ ៣២២ ដល់ ៣៤១ (ភាសាអង់គ្លេស)។

[39] សេចក្ដីជូនដំណឹងពីបណ្ដឹងសាទុក្ខ កថាខណ្ឌ ៨(៣)។

[40] *សំណុំរឿង ០០២* សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកសហឧក្រិដ្ឋកម្មរួមទម្រង់ទី III ជាទម្រង់នៃការទទួលខុសត្រូវ ជាជម្រើសម្យ៉ាងទៀត ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E100 កថាខណ្ឌ ២០។

[41] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីសហឧក្រិដ្ឋកម្មរួមទម្រង់ទី III ជើងទំព័រ ៧១ *ដោយដកស្រង់ចេញពី រឿងក្ដី សហរដ្ឋអាមេរិក តទល់នឹង* Haesiker, សំណុំរឿងលេខ 12-489-1 ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៤៧ សាលដីកា (ដោយផ្អែកលើអង្គហេតុដូចគ្នានឹង *រឿងក្ដី សហរដ្ឋអាមេរិក តទល់នឹង* Goebell *និងអ្នកផ្សេងទៀត* ថ្ងៃទី ៦ ខែ កុម្ភៈ ដល់ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ១៩៤៦) ("រឿងក្ដី *Borkum Island*")។ សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីសហឧក្រិដ្ឋកម្មរួមទម្រង់ទី III ជើងទំព័រ ៧៥ *ដោយដកស្រង់ចេញពី រឿងក្ដី Trial of Erich Heyer និងមនុស្សប្រាំមួយអ្នកផ្សេងទៀត* តុលាការយោធាចក្រភពអង់គ្លេស ជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម Essen ថ្ងៃទី ១៨ ដល់ ១៩ និង ២១ ដល់ ២២ ខែ ធ្នូ ឆ្នាំ ១៩៤៥ UNWCC, Vol. 1 (ឆ្នាំ ១៩៤៩) ("រឿងក្ដី *Essen Lynching*")។

*រឿងក្តី Tadić*[42]។ សហឧក្រិដ្ឋកម្មរួមទម្រង់ទី III មិនមានមូលដ្ឋានក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ ១៩៩២ ទេ។

17. ទីប្រាំ សហព្រះរាជអាជ្ញាអះអាងថា "នៅពេលបច្ចុប្បន្ននេះ ការសម្រេចរបស់អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ស្តីពីសហឧក្រិដ្ឋកម្មរួមទម្រង់ទី III មានភាពខុសពីតុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការដែលមានលក្ខណៈជាអន្តរជាតិដែលជាដៃគូផ្សេងទៀត"[43]។ នៅក្នុងអំណះអំណាងរបស់ខ្លួន សហព្រះរាជអាជ្ញាមិនបានលើកឡើងថា តុលាការ ICC បានបដិសេធយ៉ាងច្បាស់ថាសហឧក្រិដ្ឋកម្មរួមមិនមែនជាទម្រង់មួយនៃការទទួលខុសត្រូវទេ[44]។ ជាងនេះទៀត ដូចបានលើកឡើង*ខាងលើ* ការលើកឡើងរបស់សហព្រះរាជអាជ្ញាមិនត្រឹមត្រូវទេ។ សហព្រះរាជអាជ្ញាគួរតែយកចិត្តទុកចំពោះថាតើ សហឧក្រិដ្ឋកម្មរួមទម្រង់ទី III បានបង្កើតជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក និងមិនត្រូវផ្តោតថាតើ ការលើកឡើងនូវការសន្និដ្ឋានផ្លូវច្បាប់ត្រឹមត្រូវនឹងនាំឲ្យមានជំហររបស់ អ.វ.ត.ក ក្នុងចំណោមតុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការដែលមានលក្ខណៈជាអន្តរជាតិផ្សេងទៀត ឬយ៉ាងណាទេ។

18. សហព្រះរាជអាជ្ញាអះអាងបន្ថែមទៀតថា[45]៖

> ភាពសុខដុម និងសង្គតិភាពនៃយុត្តិសាស្ត្រក៏ជាគោលបំណងដ៏សំខាន់នៃគោលនយោបាយផ្នែកច្បាប់អន្តរជាតិនៃប្រព័ន្ធដែលមិនមានលក្ខណៈពេញលេញនៃយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិដែលព្យាយាមសម្រេចគុណតម្លៃនៃ (ក) លទ្ធភាពដូចគ្នាចំពោះការការពារដោយច្បាប់នៅក្នុងចំណោមយុត្តាធិការអន្តរជាតិ (ខ) សច្ចភាពគតិយុត្តិចំពោះជនត្រូវចោទ និងជនជាប់ចោទនៃបទល្មើសព្រហ្មទណ្ឌអន្តរជាតិ (គ) ការញញើតពិតប្រាកដក្នុងការប្រព្រឹត្តិបទល្មើសបែបនេះតាមរយៈការអនុវត្តច្បាប់ដូចគ្នា និង (ឃ) ការផ្តល់ប្រភពសម្រាប់អនុវត្តដ៏ប្រសើរនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌជាតិ ដែលជាគោលបំណងច្បាស់លាស់របស់ អ.វ.ត.ក ក្នុងការបន្សល់ទុកនូវកេរដំណែល។

---

[42] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីសហឧក្រិដ្ឋកម្មរួមទម្រង់ទី III កថាខណ្ឌ ៣០ ដល់ ៣៥។

[43] សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ កថាខណ្ឌ ៨(៤)។

[44] សេចក្តីសម្រេចលើការបញ្ជាក់បទចោទក្នុងរឿងក្តី Lubanga កថាខណ្ឌ ៣២២ ដល់ ៣៤១។

[45] សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ កថាខណ្ឌ ៩។

ទោះបីសហព្រះរាជអាជ្ញាប្រកាន់យកគោលដៅដ៏ពិសិដ្ឋ តែគោលបំណងទាំងនេះមិនអាចសម្រេចបានដោយអនុវត្តច្បាប់ដែលមិនមានក្នុងពេលវេលាដែលពាក់ព័ន្ធទេ។ ការអនុវត្តច្បាប់ដែលមានក្នុងពេលវេលាដែលពាក់ព័ន្ធគឺផ្ទុយនឹងគោលការណ៍សច្ចភាពផ្លូវច្បាប់ ហើយដែល អ.វ.ត.ក ដើរតួនាទីជាតុលាការគំរូផងនោះ[46]។ ដើម្បីឱ្យអង្គជំនុំជម្រះតុលាការកំពូលសម្រេចតាមគោលដៅដ៏ពិសិដ្ឋដែលបានប្រកាន់យកដោយសហព្រះរាជអាជ្ញា អង្គជំនុំជម្រះគួរតែសម្រេចថាសំណើរបស់ ក.ស.ព មិនអាចទទួលយកបាន។

19. សហព្រះរាជអាជ្ញាអះអាងថា ការអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី III នៅ អ.វ.ត.ក នឹង "ផ្តល់ប្រភពសម្រាប់អនុវត្តដ៏ប្រសើរនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌជាតិ ដែលជាគោលបំណងច្បាស់លាស់របស់ អ.វ.ត.ក ក្នុងការបន្សល់ទុកនូវកេរដំណែល"[47]។ ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ ដែលត្រូវបានអនុម័តប៉ុន្មានឆ្នាំក្រោយពេល អ.វ.ត.ក ចាប់ផ្តើមដំណើរការ ប្រមូលបទល្មើសប្រល័យពូជសាសន៍[48] ឧក្រិដ្ឋកម្មសង្គ្រាម[49] និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[50]។ នៅពេលមានឱកាស សភាកម្ពុជាមិនបានបញ្ចូលទម្រង់ណាមួយនៃសហឧក្រិដ្ឋកម្មរួមទៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឬក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩[51]។ ការអនុវត្តសហឧក្រិដ្ឋកម្មរួមនៅតុលាការជាតិនឹងតម្រូវឱ្យមានការវិសោធនកម្មច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឬក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ ដោយសភាកម្ពុជា។

---

[46] អង្គជំនុំជម្រះសាលាដំបូងបានថ្លែងថា ទោះបី អ.វ.ត.ក ពុំមានយុត្តាធិការឆ្លើយតបដោយផ្ទាល់ទៅនឹងភាពខ្វះចន្លោះដូចដែលបានចោទប្រកាន់នៅក្នុងយន្តការជាតិ ក្នុងការធានាឯករាជភាពតុលាការក៏ដោយ ទោះជាយ៉ាងណាក៏ដោយ"អ.វ.ត.ក អាច<u>ជាតុលាការគំរូមួយ</u> សម្រាប់ជួយជំរុញឱ្យមានការធានានូវឯករាជភាព និងសុចរិតភាពនៅក្នុងស្ថាប័នតុលាការ" *សំណុំរឿង ០០២* សេចក្តីសម្រេចលើសំណើរបស់លោក អៀង សារី ដែលប្តឹងជំទាស់ចិត្តចំពោះលោកចៅក្រម និល ណុន និងសមណើពាក់ព័ន្ធផ្សេងៗទៀត ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ ឯកសារ E5/3 កថាខណ្ឌ ១៤ (គូសបញ្ជាក់បន្ថែម)។

[47] សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ កថាខណ្ឌ ៩។

[48] ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ មាត្រា ១៨៣ ដល់ ១៨៧។

[49] ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ មាត្រា ១៩៣ ដល់ ១៩៨។

[50] ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ មាត្រា ១៨៨ ដល់ ១៩២។

[51] ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ រួមមាន៖ "មាត្រា ២៤៖ គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ" "មាត្រា ២៥៖ និយមន័យនៃចារី" "មាត្រា ២៦៖ និយមន័យនៃសហចារី" "មាត្រា ២៧៖ និយមន័យនៃការប៉ុនប៉ង" "មាត្រា ២៨៖ និយមន័យនៃអ្នក

## III. សេចក្ដីសន្និដ្ឋាន

20. តាមសំអាងហេតុនានាដែលបានលើកឡើងខាងលើ សំណើរបស់ ក.ស.ព មិនអាចទទួលយកបានទេ។ សំណើរបស់ ក.ស.ព រំលោភបំពានទៅលើសិទ្ធិជាសារវ័ន្តរបស់ជនសង្ស័យ ដោយមានបំណងចង់ឲ្យអង្គជំនុំជម្រះប្រកាសថាទម្រង់នៃការទទួលខុសត្រូវមួយអាចអនុវត្តបាននៅ អ.វ.ត.ក ហើយវាក៏អាចអនុវត្តចំពោះជនសង្ស័យដែរ ដែលមិនមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ទេ។ ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា សំណើរបស់ ក.ស.ព អាចទទួលយកបាន ដើម្បីការពារសិទ្ធិជាសារវ័ន្តរបស់ជនសង្ស័យក្នុងការទទួលការកាត់សេចក្ដីតាមច្បាប់ជាធរមាននៅពេលដែលបទល្មើសត្រូវបានចោទប្រកាន់តែប៉ុណ្ណោះ និងសិទ្ធិទទួលបានសមភាពនៃមធ្យោបាយរវាងគូភាគីក្នុងការតទល់ក្ដី គាត់ត្រូវតែទទួលបានការអនុញ្ញាតដាក់សារណារបស់អ្នកមិនមែនជាភាគីរឿងក្ដី ដើម្បីជួយអង្គជំនុំជម្រះតុលាការកំពូលក្នុងការសម្រេចទៅលើសំណើរបស់ ក.ស.ព សុំអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី III នៅ អ.វ.ត.ក។

**អាស្រ័យហេតុនេះ** សម្រាប់សំអាងហេតុនានាដែលបានលើកឡើងខាងលើ មេធាវីការពារក្ដីស្នើសុំដោយគោរពដល់អង្គជំនុំជម្រះតុលាការកំពូលមេត្តា៖

១. សន្និដ្ឋានថាសំណើរបស់ ក.ស.ព មិនអាចទទួលយកបាន។ ឬជាជម្រើសម្យ៉ាងទៀត

២. ទទួលយកសារណារបស់អ្នកមិនមែនជាភាគីរឿងក្ដី។

សូមលោក លោកស្រីចៅក្រមមេត្តាទទួលយកសារណានេះដោយគោរព។

---

ផ្ដើមគំនិត" "មាត្រា ២៩៖ និយមន័យនៃអ្នកសមគំនិត" "មាត្រា ៣០៖ និយមន័យនៃអ្នករាជការសាធារណៈ ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត"។

ស៊ូ មូស្សេន្នី Suzana TOMANOVIĆ

មេធាវីការពារក្ដីជនសង្ស័យមួយរូបដែលមានឈ្មោះក្នុងសំណុំរឿង 00៤

ចុះហត្ថលេខានៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី **១២** ខែ **មករា** ឆ្នាំ ២០១៥